# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦០ សសរ

## សេចក្តីសម្រេច

ស្តីពី

ការបង្កើតគណៈកម្មការឯកជនភាវូបនីយកម្ម នៃក្រុមហ៊ុនចំរុះ ខាំមិនតែល និងវាយតម្លៃការងារជំនាញ នៃការប្រើប្រាស់កម្ចី ២៥០ លានយ៉េន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១.-**

បង្កើតគណៈកម្មការឯកជនភាវូបនីយកម្ម នៃក្រុមហ៊ុនចំរុះ ខាំមិនតែល និងវាយតម្លៃការងារជំនាញ នៃការប្រើប្រាស់កម្ចី ២៥០ លានយ៉េន ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | សុខ អាន | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្តម | សូ ឃុន | រដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | អនុប្រធាន |
| ៣- ឯកឧត្តម | អ៊ុក រ៉ាប៊ុន | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤- ឯកឧត្តម | ត្រាក់ សុខុន | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥- ឯកឧត្តម | ឡា ណារ៉ាត | រដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៦- ឯកឧត្តម | សយ សុខា | អគ្គលេខាធិការក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | សមាជិក |

| | | | |
|---|---|---|---|
| ៧- ឯកឧត្តម | **ចន្សី វិសុទ្ធ** | អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨- ឯកឧត្តម | **ជា វ៉ាន់ដេត** | នាយកខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី | សមាជិក |
| ៩- លោក | **ញឹក កោសលវិទ្យា** | អគ្គនាយកក្រុមហ៊ុនចំរុះ ខាំមិនតែល | សមាជិក |
| ១០- លោក | **ភាំង លាងខណ្ឌ** | ប្រធាននាយកដ្ឋានទ្រព្យសម្បិត្តរដ្ឋ ស.ហ.វ | សមាជិក |
| ១១- លោក | **ង៉ោ យុនថា** | ប្រធានការិយាល័យសហប្រតិបត្តិការទ្វេភាគី ស.ហ.វ. | សមាជិក |
| ១២- លោក | **ត្រាំ សុផល** | ប្រធានការិយាល័យទ្រព្យសម្បត្តិរដ្ឋ ស.ហ.វ. | សមាជិក |

**ប្រការ២ .-**

គណៈកម្មការមានភារកិច្ច ពិនិត្យវាយតម្លៃលើការងារឯកជនភាវូបនីយកម្ម នៃក្រុមហ៊ុនចំរុះ ខាំមិនតែល និងពិនិត្យវាយតម្លៃលើការងារជំនាញ ចំពោះការប្រើប្រាស់កម្ចី ២៥០ លានយ៉ន របស់ ចិន ដែលរាជរដ្ឋាភិបាលបានឯកភាពឱ្យក្រុមហ៊ុន AZCOM យកមកប្រើប្រាស់សម្រាប់អភិវឌ្ឍ បណ្តាញទូរគមនាគមន៍ ។

**ប្រការ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង ប្រៃសណីយ៍ និងទូរគមនាគមន៍ និងសាមីខ្លួន ដែលមានចែងក្នុងប្រការមួយ ត្រូវអនុវត្តសេចក្តី សម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចចែងក្នុងប្រការ ៣*
- *ឯកសារ-កាលប្បវត្តិ* ✓